## សេចក្តីប្រកាសព័ត៌មាន

សម្រាប់ការផ្សព្វផ្សាយ: ថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០១៥

# ធនាគារ ANZ Royal បន្តការគាំទ្រទៅដល់សហគមន៍

ធនាគារ ANZ Royal អបអរ ១០ឆ្នាំនៃការផ្តល់ជូនទៅសហគមន៍ដោយឧបត្ថម្ភប្រាក់ចំនួន ១០,០០០ ដុល្លារទៅដល់មន្ទីរពេទ្យគន្ធបុប្ផានិង កុំព្យូទ័រចំនួន២០០គ្រឿងទៅដៃគូរផ្សេងៗដូចជា៖ សហគ្រាសសង្គម ហ្វារ អង្គការដើម្បីភាពញញឹមនៃកុមារ (PSE) អង្គការ Passerelles Numeriques Cambodia និងអង្គការកុមារមេតង្គ។

លោក Grant Knuckey អគ្គនាយកធនាគារ ANZ Royal មាននិយាយថា៖  យើងខ្ញុំមានការប្តេជ្ញាផ្តល់នូវអត្ថប្រយោជន៍ដល់សហគមន៍ដែលយើង រស់នៅ។ ហេតុនេះ ទើបយើងខិតខំបំពេញការងារសង្គមដើម្បីរួមចំណែកចែករំលែក ទៅតាមលទ្ធភាពរបស់យើង។

លោកបានបន្ថែមថា៖ រយៈពេល 10 ឆ្នាំកន្លងមកនេះ បុគ្គលិករបស់យើង បានចូលរួមធ្វើការងារស្ម័គ្រចិត្តដោយចំណាយពេលវេលាជាង 45,000ម៉ោងជាមួយអង្គការក្រៅរដ្ឋាភិបាលចំនួន 100 អង្គការ ដើម្បីជួយផ្តល់ឱកាសសម្រាប់អ្នកដែលជួបការលំបាកខ្លាំងនៅប្រទេសប្រជាជនកម្ពុជា។ ប៉ុន្តែយើងជឿជាក់ថា យើងនឹងអាចបន្តធ្វើបានច្រើនជាងនេះទៀត។

នៅឆ្នាំ២០១៥ និង ២០១៦ ធនាគារ ANZ Royal បានចាប់ដៃគូជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលមួយដោយឧបត្ថម្ភប្រាក់ចំនួន 20,000 ដុល្លារ   ដើម្បីឧបត្ថម្ភគាំទ្រការអប់រំ និងផ្តល់ក្តីសង្ឃឹមដល់យុវជនកម្ពុជា។

សម្រាប់ឆ្នាំ 2016 យើងនឹងបង្កើតកម្មវិធី MoneyMinded ដែលជាកម្មវិធីអប់រំផ្នែកហិរញ្ញវត្ថុសម្រាប់សហគមន៍របស់យើង។

ធនាគារ ANZ Royal មានការប្តេជ្ញាខ្ពស់ដើម្បីផ្តល់នូវអត្ថប្រយោជន៍ដល់សហគមន៍។
តាមការចាំដៃគូរជាមួយអង្គការក្រៅរដ្ឋាភិបាល និងក្រុមសប្បុរសផ្សេងៗ យើងអាចបន្តការងារដែលជួយពង្រឹងការអប់រំ និងបង្កើនឱកាសការងារសម្រាប់អ្នកដែលជួបការលំបាកខ្លាំង។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងៈ**

កញ្ញា ជេត ច័ន្ទកណ្ណិកា
ប្រធានផ្នែកទំនាក់ទំនង
ធនាគារ ANZ Royal
ទូរសព្ទៈ 095 777 947
អ៊ីម៉ែលៈ chankanika.cheth@anz.com